**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកំពង់ធំ**
លេខ....៣៤៨៤..../១៧ សជ៣

កំពង់ធំ ថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៧

# សេចក្តីជូនដំណឹង
# ស្តីពី
# ការជ្រើសរើសបុគ្គលិកសារឡើងវិញ សម្រាប់ផែនការអនុវត្តរយៈពេល ៣ ឆ្នាំ ជំណាក់កាលទី២ ( ផអ៣ទី២ ) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សម្រាប់ស្រុកកំពង់ស្វាយខេត្តកំពង់ធំ

រដ្ឋបាលខេត្តកំពង់ធំ មានកិត្តិយសសូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាជាមន្ត្រីរាជការ និងសាធារណៈជនទាំងអស់ឲ្យបានជ្រាបថា៖ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវការជ្រើសរើសបុគ្គលិកដើម្បីបម្រើការងារក្នុងកម្មវិធីផអ៣ទី២ នៅក្នុងខេត្តកំពង់ធំដូចខាងក្រោម៖

| ល.រ | មុខតំណែង | ចំនួន | ទីកន្លែង | ប្រាក់ខែ(ដុល្លារ) |
|---|---|---|---|---|
| ១ | បុគ្គលិកគាំទ្របច្ចេកទេសស្រុក | ០១ | ស្រុកកំពង់ស្វាយ ( ១ដំណែង ) | ២៥០ |

**ក. តួនាទីភារៈកិច្ច នៃមុខតំណែងនេះមានដូចខាងក្រោម៖**

ជួយគាំទ្រដល់រដ្ឋបាលស្រុក ជាពិសេសការិយាល័យផែនការនិងគាំទ្រឃុំ សង្កាត់ ដើម្បីគាំទ្រជាចម្បងទាំងថ្នាក់ស្រុក និងឃុំសង្កាត់ ក្នុងការរៀបចំដំណើរការកសាងផែនការក្នុងការសិក្សាលទ្ធភាព គ្រប់គ្រង អនុវត្ត ត្រួតពិនិត្យគម្រោង និងក្នុងការគ្រប់គ្រងទិន្នន័យព័ត៌មានវិទ្យា និងជួយដល់ការិយាល័យពាក់ព័ន្ធទាំងឡាយក្នុងការអនុវត្តមុខងារដែលបានផ្ទេរឲ្យរដ្ឋបាលក្រុងស្រុក។

**ខ. លក្ខណៈសម្បត្តិ និងបទពិសោធន៍ការងារ**

- បញ្ចប់បរិញ្ញាប័ត្ររង ក្នុងវិស័យអភិវឌ្ឍន៍ជនបទ កសិកម្ម បរិស្ថាន មុខងារសាធារណៈការគ្រប់គ្រងធុរៈកិច្ច ច្បាប់ និងសេដ្ឋកិច្ចជាដើម (សញ្ញាប័ត្រមានកម្រិតលើសពីនេះ កាន់តែល្អប្រសើរ) និងមានបទពិសោធន៍យ៉ាងតិច៣ឆ្នាំទាក់ទងនឹងមុខតំណែងខាងលើ។
- មានការយល់ដឹងអំពីអភិបាលកិច្ច និងដំណើរការកសាងផែនការថ្នាក់ក្រុង ស្រុក និងឃុំសង្កាត់។
- មានបទពិសោធន៍ក្នុងការរៀបចំកម្មវិធីអភិវឌ្ឍន៍សមត្ថភាពដូចជា ការបណ្តុះបណ្តាល ការសម្របសម្រួលសិក្ខាសាលា និងរៀបចំរបាយការណ៍បណ្តុះបណ្តាល។
- មានការយល់ដឹងច្បាស់អំពីការរៀបចំ និងគ្រប់គ្រងគម្រោងសំណើ ការអនុវត្ត ការតាមដាន និងរៀបចំរបាយការណ៍ ជាពិសេសគម្រោងមូលនិធិក្រុង ស្រុក និងឃុំសង្កាត់។
- មានការយល់ដឹងផ្នែកគ្រប់គ្រងកិច្ចការរដ្ឋបាល និងសារពើភ័ណ្ឌទ្រព្យសម្បត្តិ។
- មានចំណេះដឹង និងជំនាញកុំព្យូទ័រ ( Ms. Office, Internet and Email ) ។
- មានបទពិសោធន៍ក្នុងការបញ្ចូល និងគ្រប់គ្រងបណ្តាញ និងទិន្នន័យ។ ថែទាំ និងជួសជុលកុំព្យូទ័រ ( ផ្នែករឹង និងផ្នែកទន់ ) និងដោះស្រាយបញ្ហាដែលជួបប្រទះក្នុងការប្រើប្រាស់កុំព្យូទ័រ ( ជាការប្រសើរ )។
- ចេះភាសាខ្មែរច្បាស់លាស់ និងមានចំណេះដឹងភាសាអង់គ្លេសសម្រាប់បំពេញការងារ។
- មានអាសយដ្ឋានក្នុងក្រុង ស្រុក គោលដៅជាការប្រសើរ។

តួនាទី ភារកិច្ច និងការទទួលខុសត្រូវលម្អិត(TOR)នៃមុខតំណែងខាងលើ ព្រមទាំងពាក្យសុំបម្រើការងាររបស់លេខាធិការដ្ឋានគ.ជ.អ.ប អាចរកបាននៅសាលាខេត្ត សាលាស្រុក និងនៅលើគេហទំព័ររបស់លេខាធិការដ្ឋាន គ.ជ.អ.ប ឬទំនាក់ទំនងមកកាន់ទូរស័ព្ទលេខ ៖

១-លោក **សួគ៌ ច័ន្ទតារា** នាយកទីចាត់ការគ្រប់គ្រងធនធានមនុស្ស **០៧៧ ៧១ ៣១ ៧១**

២-លោកស្រី **ភឿន ធារី** ប្រធានការិយាល័យគ្រប់គ្រងបុគ្គលិក **០១៧ ៩២ ១៨ ៣៥**

**០១៦ ៩២ ៤៧ ២០**

តាមរយៈE- mail៖ phoeun.theary@kpt.ncdd.gov.kh ឬ theary.phoeun@gmail.com

*បេក្ខជន ដែលមានចំណាប់អារម្មណ៍ សូម ផ្ញើពាក្យសុំបម្រើការងារមកកាន់ការិយាល័យគ្រប់គ្រងបុគ្គលិក នៃរដ្ឋបាលខេត្តកំពង់ធំរៀងរាល់ម៉ោងធ្វើការ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅរហូតដល់ ថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០១៧ វេលាម៉ោង ៥ និង ៣០នាទីល្ងាច ។

មានតែបេក្ខជនដែលមានឈ្មោះក្នុងបញ្ជីសម្រាំងបេក្ខជនអាទិភាព(Shortlist)ប៉ុណ្ណោះ ដែលនឹងទទួលបានព័ត៌មានអំពីការជ្រើសរើស។ បេក្ខជនជាស្ត្រីត្រូវបានលើកទឹកចិត្តសម្រាប់មុខតំណែងនេះ។

<u>បញ្ជាក់</u>៖ មុខតំណែងនេះ ជាប្រភេទកិច្ចសន្យាការងារធ្វើការពេញម៉ោង។ ក្នុងករណីដែលបេក្ខជនជាមន្ត្រីរាជការស៊ីវិលនោះ បេក្ខជនត្រូវដាក់ពាក្យសុំស្ថិតនៅក្នុងភាពទំនេរគ្មានប្រាក់បៀវត្សក្នុងរយៈពេលនៃការបំពេញការងារជាមួយកម្មវិធីជាតិ។៕ ✓

**អភិបាល**

**គង់ វិមាន**

**<u>ចម្លងជូន</u>** ÷

- លេខាធិការដ្ឋានគ.ជ.អ.ប
- ក្រុមប្រឹក្សាខេត្ត
  «ដើម្បីជូនជ្រាប»
- ស្រុកកំពង់ស្វាយ
- ឯកសារ-កាលប្បវត្តិ